STATE OF NEW YORK
OFFICE OF THE ATTORNEY GENERAL

ERIC T. SCHNEIDERMAN
អគ្គមេធាវី ( ATTORNEY GENERAL )

NEW YORK STATE EDUCATION DEPARTMENT
THE UNIVERSITY OF THE STATE OF NEW YORK

MARYELLEN ELIA
ស្នងការផ្នែកអប់រំ ( COMMISSIONER OF EDUCATION )
ប្រធានសកលវិទ្យាល័យរដ្ឋញូយ៉ក ( PRESIDENT OF THE UNIVERSITY OF THE STATE OF NEW YORK )

ថ្ងៃទី 27 ខែកុម្ភៈ ឆ្នាំ 2017

សកម្មភាពកាលពីពេលថ្មីៗពាក់ព័ន្ធនឹងអន្តោប្រវេសន៍ ដែលបានអនុវត្តឡើងដោយមន្ត្រីសហព័ន្ធ បានបង្កឲ្យមានការភ័យខ្លាច និងការភាន់ភាំងទូទាំងប្រទេស ។ ពលរដ្ឋរបស់រដ្ឋញូយ៉កទាំងអស់ ដែលមានទាំងភ្នាក់ងារ និងគណៈគ្រប់គ្រងរដ្ឋញូយ៉កទទួលខុសត្រូវផ្នែកការងារអប់រំ បានប្តេជ្ញាបម្រើ បានទាក់ទងដោយផ្ទាល់ជាមួយនឹងភ្នាក់ងាររបស់យើងអំពីភាពភ័យបារម្ភ និងចម្ងល់អំពីសម្មភាពទាំងអស់នេះដែលបានកើតឡើង ។ ការិយាល័យអគ្គមេធាវីរបស់រដ្ឋញូយ៉ក (New York State Office of the Attorney General (“OAG”)) និងក្រសួងអប់រំរបស់រដ្ឋញូយ៉ក (New York State Education Department (“SED”)) សរសេរលិខិតមួយច្បាប់ក្នុងថ្ងៃនេះ ដើម្បីបញ្ជាក់ជូនឡើងវិញដល់និស្សិត សាលា គ្រួសារ និងសហគមន៍ទាំងអស់ទូទាំងរដ្ឋញូយ៉ក ឲ្យបានជ្រាបថា សាលារៀនរបស់យើងនឹងបន្តនៅជាតំបន់ដែលមានសុវត្ថិភាពដដែល សម្រាប់ជាកន្លែងឲ្យនិស្សិតទាំងអស់សិក្សារៀនសូត្រ ។

ដោយអនុលោមទៅតាមច្បាប់អប់រំរបស់រដ្ឋញូយ៉ក (New York State Education Law) កុមារដែលមានអាយុលើសពីប្រាំឆ្នាំ និងនិស្សិតដែលមានអាយុក្រោមម្ភៃមួយឆ្នាំ ដែលនៅមិនទាន់អាចទទួលបានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ មានសិទ្ធិចូលរៀននៅសាលារៀនរបស់រដ្ឋ នៅតាមមណ្ឌលសិក្សាស្រុក (school district) ដែលពួកគេកំពុងរៀនសូត្រ ដោយមិនបាច់បង់ថ្លៃសិក្សាឡើយ ។ លើសពីនេះ មណ្ឌលសិក្សាស្រុកត្រូវធានាឲ្យបានថា សិស្សទាំងអស់ដែលស្ថិតក្នុងអាយុត្រូវទទួលការអប់រំជាមូលដ្ឋាន ត្រូវចូលរៀនជាសិស្សពេញម៉ោង[1] ។ **សិស្សដែលនៅមិនទាន់មានឯកសារទទួលស្គាល់ឲ្យរស់នៅលើទឹកដីសហរដ្ឋអាមេរិក ដូចទៅនឹងសិស្សជាកូនរបស់ពលរដ្ឋអាមេរិកាំងដែរ គឺមានសិទ្ធិចូលរៀនពេញម៉ោង ដរាបណាពួកគេស្ថិតនៅក្នុងរង្វង់អាយុ និងភាពតម្រូវជាអ្នកស្នាក់នៅទៅតាមការកំណត់របស់ច្បាប់ ។** តាមពិត តុលាការកំពូលសហរដ្ឋអាមេរិក (U.S. Supreme Court) បានកំណត់តាំងពីរាប់ទស្សវត្សរ៍មកហើយ នៅក្នុង *Plyler v. Doe* ថា មណ្ឌលសិក្សាស្រុកមិនអាចបដិសេធផ្តល់ការអប់រំសាធារណៈដល់សិស្សដោយឥតគិតថ្លៃ ដោយសំអាងលើ

---

[1] *សូមអាន* ច្បាប់អប់រំ ត្រង់វគ្គទី 3202(1), 3205 ។

មូលដ្ឋានគ្រឹះនៃភាពគ្មានឯកសារស្នាក់នៅ ឬភាពមិនមែនជាពលរដ្ឋអាមេរិកាំង ឬដោយសារឪពុកម្តាយ ឬអាណាព្យាបាលរបស់ពួកគេជាជនមិនមានឯកសារស្នាក់នៅឡើយ[2] ។

ក្នុងនេះដែរ OAG/SED បានគូសបញ្ជាក់ពីសារៈសំខាន់នៃសិទ្ធិរបស់សិស្សដែលមិនមានឯកសារស្នាក់នៅ ដោយចេញជាគោលការណ៍ណែនាំចំពោះមណ្ឌលសិក្សាស្រុកថា ក្នុងពេលចុះឈ្មោះចូលរៀន សាលារៀនទាំងអស់មិនត្រូវសួរសំណួរពាក់ព័ន្ធនឹងស្ថានភាពអន្តោប្រវេសន៍ ដែលអាចបង្ហាញអំពីស្ថានភាពអន្តោប្រវេសន៍របស់សិស្សឡើយ ដូចជាការស្នើសុំលេខសន្តិសុខសង្គម[3] ជាដើម។ យើងខ្ញុំក៏បានផ្តល់ជាដំបូន្មានផងដែរថា ក្នុងពេលដែលមណ្ឌលសិក្សាស្រុកត្រូវប្រមូលទិន្នន័យមួយចំនួន ដោយអនុលោមទៅតាមច្បាប់រដ្ឋ និង/ឬច្បាប់សហព័ន្ធ សាលាទាំងអស់នោះអាចធ្វើសកម្មភាពនេះបាន <u>ក្រោយពេល</u>ដែលសិស្សបានចុះឈ្មោះចូលរៀនរួចរាល់សិន ដើម្បីកុំឲ្យមានការយល់ច្រឡំថា ព័ត៌មានពាក់ព័ន្ធនឹងអន្តោប្រវេសន៍ នឹងត្រូវបានប្រើដើម្បីយកមកកំណត់អាទិភាពទទួលសិស្សឲ្យចូលរៀន[4] ។

កាលពីពេលថ្មីៗនេះ ភ្នាក់ងាររបស់យើង បានទទួលសំណួរជាច្រើន ជាពិសេសស្តីអំពីកាតព្វកិច្ចរបស់មណ្ឌលសិក្សាស្រុក ពាក់ព័ន្ធនឹងការសាកសួរដែលអាចមានពីអ្នកតំណាងផ្នែកពង្រឹងច្បាប់អន្តោប្រវេសន៍ និងគយសហរដ្ឋអាមេរិក (U.S. Immigration and Customs Enforcement (“ICE”)) បូករួមទាំងការស្នើសុំជួប ឬសុំសម្ភាសន៍ជាមួយសិស្ស ឬការស្នើសុំបើកមើលសំណុំទិន្នន័យរបស់សិស្សផងដែរ ។ ដូចអ្វីដែលអ្នកគ្រប់គ្នាបានដឹងរួចមកហើយ ច្បាប់ផ្សេងៗ បានកំណត់កាតព្វកិច្ចផ្នែកច្បាប់ ចំពោះមណ្ឌលសិក្សាស្រុក ពាក់ព័ន្ធនឹងការពង្រឹងច្បាប់ លើការសាកសួរសិស្សនៅតាមសាលា និងការ សម្ងាត់នៃកំណត់ត្រាព័ត៌មានសិស្ស ដោយច្បាប់ទាំងអស់នោះ មានរួមទាំងក្រមតុលាការគ្រួសាររដ្ឋញូយ៉ក (New York Family Court Act (“NYFCA”)) និងក្រមសិទ្ធិការអប់រំគ្រួសារ និងក្រមឯកជនភាព (Family Educational Rights and Privacy Act (“FERPA”)) របស់សហព័ន្ធ ។ ការធ្វើខុសចំពោះកាតព្វកិច្ចទាំងនេះ គឺបើទោះបីជាយើងគ្រាន់តែបំពេញតាមសំណើសុំរបស់អាជ្ញាធរអន្តោប្រវេសន៍សហព័ន្ធក៏ដោយ ក៏អាចបង្កឲ្យមានការទទួលខុសត្រូវដោយមណ្ឌលសិក្សាស្រុកផងដែរ ។ ដោយសារតែមូលហេតុនេះហើយ ដែលនាំឲ្យភ្នាក់ងាររបស់យើងលើកទឹកចិត្តដល់បុគ្គលិកមណ្ឌលសិក្សាស្រុកទាំងអស់ ត្រូវតែពិគ្រោះយោបល់ជាមួយនឹងស្នងការសាលា និងមេធាវីរបស់សាលាខ្លួនជាបន្ទាន់ បន្ទាប់ពីខ្លួនទទួលបានសំណើណាមួយ ពីមន្ត្រីអន្តោប្រវេសន៍សហព័ន្ធ ។ នៅមុនពេលឆ្លើយតបចំពោះសំណើសុំបែបនេះ បុគ្គលិកមណ្ឌលសិក្សាស្រុក ត្រូវពិភាក្សាជាមួយស្នងការ និងមេធាវីសាលារបស់ខ្លួនសិន ដើម្បីកំណត់ថា តើការធ្វើតាមសំណើបែបនេះ អាចនាំឲ្យមណ្ឌលសិក្សាស្រុក ប្រព្រឹត្តិបំពានចំពោះច្បាប់ណាមួយដែលនៅជាធរមានដែរឬទេ ។

---

[2] *Plyler v. Doe,* 457 U.S. 202 (1982) *សូមអានផងដែរចំពោះ បណ្តឹងឧទ្ធរណ៍ប្លាតា (Appeal of Plata*), 40 Ed. តំណាងក្រសួង 552 សេចក្តីសម្រេចលេខ 14,555 ។

[3] *សូមអាន ឧទាហរណ៍* Cosimo Tangorra, Jr., *លិខិត "ជូនចំពោះសហការី"* ក្រសួងអប់រំរដ្ឋញូយ៉ក (New York State Education Department) (ទី 10 កញ្ញា 2014) http://www.p12.nysed.gov/sss/documents/EducationalServicesforRecentlyArrivedUnaccompaniedChildren.pdf.

[4] ជាមួយនឹងសេចក្តីសំអាងជាក់លាក់ចំពោះការកំណត់អត្តសញ្ញាណសន្តិសុខសង្គម, SED មិនតម្រូវឲ្យមណ្ឌលសិក្សាស្រុក ប្រមូលប័ណ្ណសន្តិសុខសង្គម ឬលេខសន្តិសុខសង្គមរបស់សិស្ស សម្រាប់បម្រើគោលបំណងអ្វីមួយ ឬនៅពេលណាមួយឡើយ គឺមិនថានៅមុនពេល ឬក្រោយពេលសិស្សបានចុះឈ្មោះចូលរៀនរួចហើយក្តី ។

*ការស្នើសុំជួប ឬស្នើសុំសម្ភាសន៍សិស្ស* ។ **<u>វាជាជំហរជាយូរមកហើយរបស់ SED ដែលមិនអនុញ្ញាតឲ្យមន្ត្រីពង្រឹងច្បាប់ បណ្តេញសិស្សចេញពីបរិវេណសាលា ឬសួរចម្លើយសិស្ស ដោយមិនមានការយល់ព្រមពីឪពុកម្តាយ ឬពីបុគ្គលដែលមាននាមជាអាណាព្យាបាលរបស់សិស្សឡើយ</u>** គឺលើកលែងតែក្នុងស្ថានភាពជាក់លាក់មួយចំនួនតូចប៉ុណ្ណោះ ( *ជាអាទិ៍* នៅពេលដែលមន្ត្រីពង្រឹងច្បាប់មានដីកាដែលនៅមានសុពលភាព ឬនៅពេលដែលមានការប្រព្រឹត្តបទឧក្រិដ្ឋក្នុងបរិវេណសាលា[5] ) ។ មន្ត្រីសាលាត្រូវបានលើកទឹកចិត្តឲ្យសហកាជាមួយនឹងការពង្រឹងច្បាប់ នៅក្នុងកម្រិតដែនកំណត់នៃច្បាប់ និងគោលនយោបាយរបស់សាលា ។ យើងសូមធ្វើការណែនាំយ៉ាងមុតមាំថា នៅពេលមានមន្ត្រី ICE ឬមន្ត្រីអន្តោប្រវេសន៍ណាផ្សេងទៀតរបស់សហព័ន្ធបង្ហាញខ្លួនក្នុងបរិវេណសាលា ដើម្បីចង់ជួបសិស្សណាមួយ ( ដើម្បីសម្ភាសន៍និង/ឬសួរសំណួរនានា ) មណ្ឌលសិក្សាស្រុក ត្រូវណែនាំដល់បុគ្គលិករបស់ខ្លួនទាំងអស់ ឲ្យទាក់ទងជាមួយនឹងស្នងការ និងមេធាវីរបស់មណ្ឌលសិក្សាស្រុកជាបន្ទាន់ ដើម្បីស្នើសុំគោលការណ៍ណែនាំ ជាពិសេសគឺដោយអនុលោមទៅតាមភារកិច្ចរបស់ខ្លួនក្រោមច្បាប់អប់រំ, *Plyler* និង NYFCA នៅមុនពេលអនុញ្ញាតឲ្យមន្ត្រីរូបនោះជួបសិស្ស ។

*ការស្នើសុំបើកមើលកំណត់ត្រាព័ត៌មានរបស់សិស្ស* ។ គឺស្រដៀងគ្នាដូចខាងលើដែរ ភ្នាក់ងាររបស់យើងបានណែនាំថា ក្រោយពេលទទួលបានការស្នើសុំពីមន្ត្រីអន្តោប្រវេសន៍ សុំបើកមើលកំណត់ត្រាព័ត៌មានការអប់រំរបស់សិស្ស មណ្ឌលសិក្សាស្រុក ត្រូវពិភាក្សាជាមួយមេធាវីសាលាជាបន្ទាន់ ដោយសារថា ការធ្វើតាមសំណើបែបនេះ ដើម្បីលាតត្រដាងព័ត៌មាន អាចជាការបំពានចំពោះច្បាប់ FERPA [6] ។ ជាទូទៅ ច្បាប់ FERPA ហាមឃាត់មណ្ឌលសិក្សាស្រុក ដែលទទួលបានមូលនិធិសហព័ន្ធ មិនឲ្យបញ្ចេញព័ត៌មានសម្ងាត់ផ្ទាល់ខ្លួន ( personally identifiable information (“PII”)) ដែលមាននៅក្នុងកំណត់ត្រាព័ត៌មានរបស់សិស្ស ដោយមិនមានការយល់ព្រមពីឪពុកម្តាយ ឬពីសិស្សដែលមានអាយុអាចផ្តល់ការអនុញ្ញាតិបាន ។ ច្បាប់ FERPA អនុញ្ញាតឲ្យលាតត្រដាងព័ត៌មានបែបនេះបាន ដោយមិនបាច់មានការយល់ព្រម តែក្នុងករណីដែលការលាតត្រដាងបែបនេះ ត្រូវធ្វើឡើងទៅតាមលក្ខ័ណ្ឌជាក់លាក់មួយចំនួន ដែលមានចែងនៅក្នុងបទបញ្ញត្តសម្រាប់

---

[5] *សូមអាន ឧទាហរណ៍* N.Y.S.E.D. នៃឱវាទមេធាវី 91 (ថ្ងៃទី 17 ខែមិថុនា ឆ្នាំ 1959) (“មិនមានមន្ត្រីណាមួយអាចយកសិស្សចេញពីក្នុងសាលា ក្នុងពេលដែលសិស្សបានចុះឈ្មោះចូលរៀនត្រឹមត្រូវ ដោយមិនមានការអនុញ្ញាតពីឪពុកម្តាយសិស្សដើម្បីសាកសួរឡើយ”) *សូមអានផងដែរចំពោះ* N.Y.S.E.D. នៃឱវាទមេធាវី 148 (ថ្ងៃទី 23 ខែកុម្ភៈ ឆ្នាំ 1965) (“ជាពិសេសសាលាមិនអាចឃុំសិស្សសម្រាប់គោលបំណងឲ្យមន្ត្រីពង្រឹងច្បាប់ ឬភាគីទីបីផ្សេងទៀត មកសួរចម្លើយសិស្ស ឬយកសិស្សចេញពីសាលាដោយមូលហេតុណាមួយឡើយ”) ។ ជំហរនេះ គឺអាស្រ័យលើច្បាប់ផ្សេងៗ បូករួមទាំង ( *ក្នុងចំណោមច្បាប់ផ្សេងៗទៀត (inter alia)* ), NYFCA ដែលតម្រូវឲ្យមន្ត្រីនគរបាល ត្រូវខិតខំគ្រប់មធ្យោបាយដើម្បីទាក់ទងជាមួយឪពុកម្តាយសិស្ស ឬនរណាម្នាក់ដែលទទួលខុសត្រូវចំពោះការថែទាំសិស្សជាបន្ទាន់ នៅពេលដែលសិស្សមានអាយុក្រោម 16ឆ្នាំ ត្រូវបានចាប់ឃុំដោយមន្ត្រីពង្រឹងច្បាប់ ហើយជាបន្ថែមទៀត ច្បាប់នេះបញ្ជាក់ថាពួកគេមិនអាចសួរចម្លើយក្មេងបែបនេះឡើយ លុះត្រាតែ និងរហូតដល់ឪពុកម្តាយ ឬអាណាព្យាបាលរបស់គេ ( បើមានវត្តមាន ) ទទួលបានការណែនាំអំពីសិទ្ធិរបស់សិស្ស ហើយមានឱកាសចូលរួមស្តាប់ការសួរចម្លើយសិស្សនោះ ។ *សូមអាន* ក្រមតុលាការគ្រួសាររដ្ឋញូយ៉ក ( N.Y. Family Court Act ) វគ្គទី 305.2; <u>សាច់រឿងនៃ Jimmy D ( Matter of Jimmy D.,</u> ) 15 N.Y.3d 417 (2010) ។

[6] *សូមអាន* 20 ក្រមសហរដ្ឋអាមេរិក ( U.S.C.) វគ្គទី 1232g ។

អនុវត្តច្បាប់នេះ ។ លក្ខ័ណ្ឌជាក់លាក់បែបនេះ មានរួមបញ្ចូលនូវការស្នើសុំជាក់លាក់ពីបុគ្គលស្របច្បាប់ពីរដ្ឋាភិបាលសហព័ន្ធ[7] ។ **ទោះជាយ៉ាងណាក៏ដោយ ការស្នើសុំពី ICE ឬមន្ត្រីអន្តោប្រវេសន៍ផ្សេងទៀតរបស់សហព័ន្ធ ដើម្បីសុំបើកមើល PII របស់សិស្ស ចេញពីកំណត់ត្រាព័ត៌មានការអប់រំ គឺមិនបានបង្ហាញពីការសមស្របតាមច្បាប់ FERPA ណាមួយឡើយ លើកលែងតែចំពោះបទបញ្ញត្តិទូទៅដែលថាឪពុកម្តាយ ឬសិស្សដែលមានអាយុអាចផ្តល់ការអនុញ្ញាតិបាន ត្រូវយល់ព្រមឲ្យមានការលាតត្រដាងព័ត៌មានប្រភេទនេះដល់ភាគីទីបី**[8] ។

ការិយាល័យ SED នៃគោលនយោបាយអប់រំ (P-12 Education Policy) ក៏បានចេញគោលការណ៍ណែនាំ ក្នុងថ្ងៃនេះផងដែរ ដល់សាលា និងមណ្ឌលសិក្សាស្រុកទាំងអស់ ស្តីអំពីក្រមនៃសេចក្តីថ្លៃថ្នូរបស់សិស្សទាំងអស់ (Dignity for All Students Act ("DASA")) ពាក់ព័ន្ធនឹងរបាយការណ៍ទាំងអស់ដែលពាក់ព័ន្ធនឹងហេតុការណ៍នៃការបង្កការរំខាននៅក្នុងសាលារៀននៅទូទាំងប្រទេសកាលពីសប្តាហ៍កន្លងទៅថ្មីៗនេះ ។ គោលការណ៍នោះ នឹងអាចរកបាននៅទីនេះ ៖ http://www.p12.nysed.gov/dignityact/documents/dasa-guidance.pdf ។

ក្នុងពេលដែលមានការសួរសំណួរជាច្រើន ថាតើសកម្មភាពពាក់ព័ន្ធនឹងអន្តោប្រវេសន៍បែបណា ដែលរដ្ឋាភិបាលសហព័ន្ធនឹងអនុវត្ត វាជាប្រការសំខាន់ដែលយើង ក្នុងនាមជាអ្នកអប់រំ និងមន្ត្រីរដ្ឋាភិបាល ត្រូវក្រើនរំឭកដល់សហគមន៍សាលារៀនរបស់យើង អំពីសារៈសំខាន់នៃការរួមបញ្ចូល និងសិទ្ធិរបស់សិស្សទាំងអស់ ក្នុងការទទួលបានការអប់រំដោយមិនត្រូវមានការភ័យខ្លាចចំពោះការផ្ញាញ់/សងសឹក ដោយសារតែខ្លួនមានវត្តមានក្នុងសាលាឡើយ ។ ថ្នាក់រៀនរបស់យើងត្រូវបន្តស្ថិតនៅជាកន្លែងដែលមានសុវត្ថិភាព ចំពោះសិស្សទាំងអស់ ។ ជាថ្មីម្តងទៀត យើងសូមថ្លែងអំណរគុណចំពោះការងារទាំងអស់ដែលអ្នកបានធ្វើ ដើម្បីគាំពារសិស្សរបស់យើង គ្រួសារ និងសហគមន៍ ។

ដោយក្តីរាប់អានអំពីយើងខ្ញុំ

| | |
|---|---|
| MaryEllen Elia | Eric T. Schneiderman |
| ស្នងការផ្នែកអប់រំ (Commissioner of Education) | អគ្គមេធាវី (Attorney General) |

[7] អនុលោមទៅតាម 34 ក្រមបទបញ្ញត្តិសហព័ន្ធ (C.F.R.) វគ្គទី99.31(a)(3) ព័ត៌មានអាចត្រូវបានលាតប្រដាងដល់ (ទៅតាមភាពតម្រូវនៃ 34 C.F.R. វគ្គទី 99.35) អ្នកតំណាងរបស់នាយកការិយាល័យគណនេយ្យភាពរបស់រដ្ឋាភិបាល (U.S. Comptroller General) អគ្គមេធាវីសហរដ្ឋអាមេរិក (U.S. Attorney General) លេខាធិការក្រសួងអប់រំសហរដ្ឋអាមេរិក (Secretary of the U.S. Department of Education) ឬអាជ្ញាធរអប់រំរដ្ឋ ឬមូលដ្ឋាន (State and local educational authorities) ។

[8] *សូមអាន* 34 C.F.R. វគ្គទី 99.31 ។